
Kids of Destiny®
Reaching the Next Generation
www.kidsofdestiny.org

## 4.01 ក្មេងប្រុសដែលបានស្តាប់តាមព្រះអម្ចាស់

**១ សាំយូអែល ១-៣**

តាំងពីយូរណាស់មកហើយ មានបុរសម្នាក់ឈ្មោះអែលកាណា មានប្រពន្ធពីរ ឈ្មោះហាណា និងពេនីណា ពេនីណាមានកូន តែហាណាមិនមានទេ។ តាមទំនៀមទម្លាប់មួយ ជារៀងរាល់ឆ្នាំអែលកាណា និងភរិយារបស់គាត់បាននាំយកតង្វាយរបស់គាត់មកដាក់នៅលើត្រសាល ដើម្បីថ្វាយបង្គំព្រះអម្ចាស់។ រាល់ពេលដែលពេនីណាបានលេងសើច និងសើចចំអកឲ្យហាណា រហូតដល់នាងយំព្រោះព្រះមិនបានប្រទានកូនឲ្យនាងទេ។ នៅឆ្នាំនោះ ពេលពួកគេបានទៅដល់ត្រសាល ហាណាបានយំ ហើយបានថ្វាយដួងចិត្តនាងដល់ព្រះដោយការអធិស្ឋានថា "ព្រះអង្គអើយ បើព្រះអង្គប្រទានកូនប្រុសមួយដល់ទូលបង្គំ កូននោះនឹងបម្រើទ្រង់ពេញមួយជីវិត" ។

នៅពេលដែលសម្តេចសង្ឃម្នាក់ឈ្មោះអេលី បានឃើញហាណាអធិស្ឋានយ៉ាងខ្លាំង ហើយយំបែបនេះ គាត់ច្រឡំថាហាណាស្រវឹង ហើយបានស្តីបន្ទោសនាង ប៉ុន្តែហាណានិយាយថា "ខ្ញុំខូចចិត្តហើយ។ ខ្ញុំបានថ្វាយដួងចិត្តខ្ញុំដល់ព្រះអម្ចាស់"។ អេលីបានប្រាប់នាងថា "សូមទៅដោយសុខសាន្តចុះ" ហើយសូមឲ្យព្រះអម្ចាស់ប្រទានអ្វីដែលអ្នកបានសុំ"។ ហាណាបានត្រឡប់មកផ្ទះវិញ ហើយព្រះបានឆ្លើយតបការអធិស្ឋានរបស់នាង ហើយមួយឆ្នាំក្រោយមកនាងក៏បានផ្តល់កំណើតដល់ទារកប្រុសម្នាក់ ដែលនាងដាក់ឈ្មោះថា សាំយូអែល ដែលមានន័យថា "បានសុំពីព្រះ" ។ នៅពេលសាំយូអែលលែងជាទារកតូចទៀតហើយនោះ ហាណាបាននាំគាត់មកឯអេលី ហើយនិយាយទៅកាន់គាត់ថា "ព្រះអម្ចាស់បានប្រទានក្មេងប្រុសនេះមកឲ្យខ្ញុំហើយ ឥឡូវនេះខ្ញុំថ្វាយកូនប្រុសនេះ ដើម្បីបម្រើព្រះ អម្ចាស់វិញ" ។ ដូច្នេះចាប់ពីពេលនោះមក សាំយូអែលរស់នៅជាមួយអេលី ហើយបម្រើព្រះយ៉ាងស្មោះត្រង់នៅឯត្រសាល ។

ជារៀងរាល់ឆ្នាំ អែលកាណា និងហាណាបានមកលេងសាំយូអែល ហើយពួកគេយកសម្លៀកបំពាក់ថ្មី មកជូនគាត់។ ក្មេងប្រុសសាំយូអែលបានធំឡើង នៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់ ហើយបានគាប់ព្រះហឫទ័យព្រះអម្ចាស់ និងប្រជាជនទាំងមូល។ ព្រះក៏បានប្រទានកូនប្រុសឲ្យហាណា៣នាក់ និងកូនស្រី២នាក់ទៀត។ អេលីគឺជាសម្តេចសង្ឃ ហើយកូនប្រុសពីរនាក់របស់គាត់ក៏បានបម្រើព្រះជាសង្ឃដែរ។ ទោះយ៉ាងណាកូនប្រុសរបស់គាត់ បានធ្វើរឿងអាក្រក់ៗជាច្រើន ដែលធ្វើឱ្យព្រះអាប់ឱននិងខកព្រះទ័យជាខ្លាំង ជាអកុសលអេលីមិនបានធ្វើអ្វីទាំងអស់ចំពោះរឿងនេះ។ នៅយប់មួយពេលសាំយូអែលដេកលក់យ៉ាងលឿន គាត់បានភ្ញាក់ឡើងដោយសំឡេងមួយ ដែលហៅឈ្មោះគាត់ ។ គាត់បានរត់ទៅរកអេលី ដោយគិតថាអេលីកំពុងហៅគាត់ ។ លោកឆ្លើយថា "បាទខ្ញុំនៅទីនេះ! ប៉ុន្តែ អេលីឆ្លើយថា មិនបានហៅទេ ឯងត្រឡប់ទៅដេកវិញទៅ ។ ប៉ុន្តែរឿងនេះបានកើតឡើងម្តងទៀត ជាពីរដង ហើយអេលីបានប្រាប់ថា វាត្រូវតែជាព្រះអម្ចាស់ដែលហៅសាំយូអែល ។

## 4.01 **ក្មេងប្រុសដែលបានស្តាប់តាមព្រះអម្ចាស់**
**សេចក្តីណែនាំសម្រាប់គ្រូបង្រៀន**
**កំណត់សម្គាល់**:

1. មានពេលមួយ មានបុរសម្នាក់ឈ្មោះអែលកាណា មានប្រពន្ធពីរ ឈ្មោះហាណា និងពេនីណា ។ ពេនីណាមានកូន តែហាណាមិនមានកូនទេ ។ ហេតុនេះធ្វើឲ្យនាងពិបាកចិត្តជាខ្លាំង ។
2. រៀងរាល់ឆ្នាំ ក្រុមគ្រួសាររបស់អែលកាណា បានទៅព្រះវិហារដើម្បីថ្វាយបង្គំ នៅឆ្នាំពិសេសនេះហាណាបានថ្វាយចិត្តនាងដល់ព្រះ ហើយនាងបានទូលទៅព្រះថា "ប្រសិនបើទ្រង់នឹងផ្តល់ឱ្យនាងនូវកូនមួយ នាងនឹងឃើញថា កូននាងនឹងបម្រើព្រះពេញមួយជីវិត ។
3. ព្រះទ្រង់បានឆ្លើយតបការអធិស្ឋានរបស់ហាណា ។ មួយឆ្នាំក្រោយមកនាងមានកូនប្រុសមួយ ដែលដាក់ឈ្មោះថា សាំយូអែល ដែលមានន័យថា "បានសូមពីព្រះ" ។
4. នៅពេលសាំយូអែលលែងជាទារកតូចទៀតហើយនោះ ហាណាបានឲ្យគាត់ទៅសម្តេចសង្ឃម្នាក់ឈ្មោះ អេលី សាំយូអែលបានរៀនបម្រើព្រះអម្ចាស់ ពេលរស់នៅជាមួយអេលី ។
5. នៅយប់មួយ សាំយូអែលបានឮសម្លេងមួយដែលហៅឈ្មោះគាត់ គាត់គិតថា អេលីបានហៅគាត់ ប៉ុន្តែអេលីបាននិយាយថា មិនមែនជាគាត់ទេ ។ នៅពេលដែលកើតឡើងម្តងទៀត អេលីយល់ថាវាជាការដែលព្រះទ្រង់បានហៅសាំយូអែលហើយ ។

### សំណួរ
១) ហេតុអ្វីបានជាភរិយារបស់អែលកាណា គឺអ្នកស្រីហាណា ពិបាកចិត្ត?
២) តើហាណាបាន អធិស្ឋានទៅព្រះអម្ចាស់ថាម៉េច?
៣) តើហាណាដាក់ឈ្មោះអ្វីឲ្យកូនគាត់?
៤) តើហាណាបានយកសាំយូអែលទៅរស់នៅឯណា?
៥) តើសាំយូអែលបានឮសម្លេងនរណា ហៅឈ្មោះគាត់នៅពេលយប់?

### ចម្លើយ
១) ហាណាពិបាកចិត្ត ព្រោះមិនអាចមានកូន។
២) ហាណាបានអធិស្ឋានទៅព្រះថា បើនាងអាចមានកូនប្រុសមួយ នាងនឹងឲ្យគេបម្រើព្រះអម្ចាស់ជារៀងរហូត។
៣) ហាណាបានដាក់ឈ្មោះកូនប្រុសរបស់គាត់ថា **សាំយូអែល** ។
៤) ហាណាបានយកសាំយូអែលឲ្យរស់នៅជាមួយសម្តេចសង្ឃអេលី ។
៥) នៅយប់មួយ សាំយូអែលបានឮព្រះអម្ចាស់ហៅឈ្មោះរបស់គាត់ ។




www.kidsofdestiny.org